កម្មវិធី Health Home ផ្តល់ជូន ៖

- ការគ្រប់គ្រងការថែទាំគ្រប់ជ្រុងជ្រោយ ។
- ការសម្របសម្រួលការថែទាំ និងការលើកកម្ពស់សុខភាព ។
- ការរៀបគម្រោងអន្តរកម្ម ។
- ជំនួយបុគ្គល និងគ្រួសារ ។
- ការបញ្ជូនទៅសេវាកម្មជំនួយសហគមន៍ និងសង្គ្រ៉មដែលពាក់ព័ន្ធ ។

Health Home

វាជាការសម្របសម្រួលការថែទាំដើម្បី ធ្វើឲ្យសុខភាពរបស់អ្នកប្រសើរឡើង ។

ការសម្របសម្រួលការ
ថែទាំសម្រាប់សុខភាព
កាន់តែល្អ

កម្មវិធី Health Home

...សម្រាប់ជីវិត
កាន់តែប្រសើរ!

ប្រើសេវាកម្ម **Health Home** ដើម្បីសម្របសម្រួលសេវាកម្មសុខភាព និងសងមរបស់អ្នក ព្រមទាំង *ធ្វើឲ្យជីវិតរបស់អ្នកប្រសើរឡើង* ។

HCA 22-860 CA (7/16) Cambodian

តើមានផលប៉ះពាល់អ្វីខ្លះដល់អ្នក?

សេវាកម្ម Health Home ជួយអ្នកក្នុងដំណើរសុខភាពរបស់អ្នក ។ ការចូលរួមរបស់អ្នកគឺដោយស្ម័គ្រចិត្ត ។ វាមិនប៉ះពាល់ភាពមានសិទ្ធិទទួលបានសេវាកម្មផ្សេងទៀត ឬសិទ្ធិប្តឹង និងប្តឹងឧទ្ធរណ៍របស់អ្នកទេ ។

សូមទូរស័ព្ទទៅលេខ
1-800-562-3022
សម្រាប់ព័ត៌មានបន្ថែម

តើអ្វីជា Health Home?

Health Home មិនមែនជាទីកន្លែងទេ ។ វាជាសំណុំនៃសេវាកម្មដើម្បីជួយអ្នកបើអ្នកមានស្ថានភាពរ៉ាំរ៉ៃធ្ងន់ធ្ងរ ហើយមានតម្រូវការលើសពីសេវាកម្មវេជ្ជសាស្ត្រ ឬសង្គមមួយ ។

សេវាកម្ម Health Home អាចធ្វើឲ្យអ្វីៗដំណើរការរលូនរវាងជំនួយសេវាកម្មវេជ្ជសាស្ត្រ និងសង្គមរបស់អ្នក ។ វាអាចជួយកាត់បន្ថយការទៅមន្ទីរពេទ្យ និងបន្ទប់សង្គ្រោះបន្ទាន់ និងជួយសុខភាព សុខុមាលភាពទូទៅ និងការថែទាំខ្លួនរបស់អ្នក ។

តើសេវាកម្មដំណើរការយ៉ាងដូចម្តេច?

- សេវាកម្ម Health Home ត្រូវបានគ្រប់គ្រងតាមរយៈទីភ្នាក់ងារការសម្របសម្រួលការថែទាំ ។
- អ្នកសម្របសម្រួលការថែទាំជួបជាមួយអ្នកដើម្បីជួយអ្នកក្នុងការបង្កើតផែនការសកម្មភាពសុខភាពរបស់អ្នក ។
- អ្នកសម្របសម្រួលការថែទាំរក្សាទំនាក់ទំនងជាមួយអ្នក និងទីភ្នាក់ងារដែលជួយអ្នក ដើម្បីធ្វើឲ្យអ្វីៗដំណើរការល្អ ។
- បើអ្នកចូល និងចេញពីមន្ទីរពេទ្យ អ្នកសម្របសម្រួលការថែទាំនឹងជួយក្នុងការរៀបអន្តរកម្មរបស់អ្នក ។
- បើអ្នកមានការលំបាកក្នុងការទទួលបានជំនួយដែលអ្នកត្រូវការ អ្នកសម្របសម្រួលការថែទាំអាចជួយអ្នកក្នុងការធ្វើការជាមួយអ្នកផ្តល់សេវាកម្ម និងទីភ្នាក់ងារសុខភាពផ្លូវចិត្ត ឬការញៀនសារធាតុគីមីដើម្បីទទួលបានការថែទាំ ។

តើសេវាកម្មទាំងនេះសម្រាប់អ្នកមែនទេ?

អ្នកអាចមានសិទ្ធិទទួលបាន បើអ្នក ៖

- ជាអតិថិជន Medicaid
- មានស្ថានភាពរ៉ាំរ៉ៃធ្ងន់ធ្ងរ និង
- ស្ថិតក្នុងហានិភ័យដាក់លើកទីពីរ ។

តើវាត្រូវចំណាយប៉ុន្មាន?

មិនមានទេ - វាជាសេវាកម្មឥតគិតថ្លៃ ។

តើវានឹងធ្វើអ្វីខ្លះឲ្យអ្នក?

- ផ្តល់ជំនួយដើម្បីជួយអ្នកចាត់ចែងតម្រូវការវេជ្ជសាស្ត្រ និងសង្គមដែលសាំញ ាំ ។
- ផ្តល់ជំនួយដើម្បីស្វែងរក និងទទួលបានសេវាកម្ម:ពេលវេលាក្នុងសហគមន៍របស់អ្នក ។

តើអ្នកចាប់ផ្តើមយ៉ាងដូចម្តេច?

- ពេលដែលអ្នកសម្របសម្រួលការថែទាំទាក់ទងអ្នក ប្រាប់ពួកគេថាអ្នកចង់ចូលរួម ។
- បន្ទាប់មក ធ្វើការជាមួយអ្នកសម្របសម្រួលការថែទាំ ធ្វើផែនការសកម្មភាពសុខភាព និងចាប់ផ្តើមធ្វើ!

តើវានឹងផ្ទាស់ប្តូរអ្នកដែលអ្នកធ្វើការជាមួយឥលូវនេះទេ?

អ្នកអាចបន្តធ្វើការជាមួយមនុស្សដដែល - កម្មវិធីនឹងគ្រាន់តែបញ្ជូលមនុស្សម្នាក់ដើម្បីជួយអ្នកបង្កើត និងតាមដានផែនការសកម្មភាពសុខភាពរបស់អ្នក ។ អ្នកអាចបន្តធ្វើការជាមួយ ៖

- អ្នកផ្តល់ការថែទាំដែលបានបង់ប្រាក់របស់អ្នក ។
- អ្នកផ្សេងទៀតដែលអ្នកធ្វើការជាមួយ (ឧទាហរណ៍ គ្រូពេទ្យ គិលានុបដ្ឋាយិកា គ្រូពេទ្យព្យាបាលរាងកាយ អ្នកប្រឹក្សាសុខភាពផ្លូវចិត្ត និងបុគ្គលិកការញៀនសារធាតុគីមី) ។
- ទីភ្នាក់ងារចាស់ជរាតំបន់របស់អ្នក និងអ្នកគ្រប់គ្រងសំណុំរឿងផ្សេងទៀត ។

Washington State Health Care Authority

Washington State Department of Social & Health Services
Transforming lives